ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៥១៥ "ឃ"

ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២

សំណុំរឿងព្រហ្មទណ្ឌលេខ ២៧០១

ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

សំណុំរឿងស៊ើបសួរលេខ ២០៤១

ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

សំណុំរឿងជំនុំជម្រះលេខ ៣៧៩៨

ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ០២ និង ៣០ នាទីរសៀល នៅសាលសវនាការទី៥ ដោយមានសមាសភាព ៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៧០១ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted]សុវ៉ែត្ត ហៅ ឡោក ភេទ ប្រុស អាយុ ២៣ ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅផ្ទះគ្មានលេខ ភូមិត្រពាំងគល់ សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ញ៉ាញ់ "រស់" ម្តាយឈ្មោះ [redacted] ម៉ាឡា "រស់" ប្រពន្ធឈ្មោះ [redacted] ស្រីណាង កូនគ្មាន ជានីតិជន ទោសពីមុន គ្មាន ។ (តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨១៣ "វ" ដ.ឃ.ដ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១) ម១ ។

២-ឈ្មោះ [redacted] សុឃន់ ហៅ ឡៅ ភេទ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅបន្តប់ជួល ភូមិត្រពាំងគល់ សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឃុន "រស់" ម្តាយឈ្មោះ [redacted] អួន "ស្លាប់" នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។ (តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨១២ "វ" ដ.ឃ.ដ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១) ម១ ។

ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted]សុវ៉ែត្ត ហៅ ឡោក ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សុឃន់ ហៅ ឡៅ ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ២៣ និង៣០នាទី មានឈ្មោះ [redacted] សុវ៉ន្ត និងបក្ខពួកឈ្មោះ [redacted] សុយន់ ភេទ ប្រុស បានធ្វើសកម្មភាពយកដាវកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] សុភ័ក្រ ភេទ ប្រុស និងឈ្មោះ [redacted] ជាន់ណា ភេទ ប្រុស នៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ បណ្តាលឱ្យមានរបួសត្រង់ដៃ រួចក៏នាំគ្នាជិះម៉ូតូ ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២១ ពាក់ផ្លាកលេខ ភ្នំពេញ 1IQ-8212 រត់គេចបាត់ ទើបឈ្មោះ [redacted] ម៉ែងគា ក៏បានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលកំបូល ។ រហូតដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ សមត្ថកិច្ចបានចុះស្រាវជ្រាវឈានដល់ការឃាត់ខ្លួនជនត្រូវចោទទាំង ០២ ខាងលើ នាំមកសាកសួរ នៅអធិការដ្ឋាននគរបាលខណ្ឌកំបូល តែម្តង ។

-បានឃើញរបាយការណ៍សំយោគលេខ ០៣៥ / ២១ រ.ប.ក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌកំបូល នៃស្នងការនគរបាលរាជធានីភ្នំពេញ ។

-បានឃើញកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១១៥៣ រ.វ.ត ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២០៤៩ អ.យ.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ៣៦៣៤ អ.យ.ណ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៩០៤ "ប" ដ.ដ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបង្គាប់រក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ ៧៣៣៤ "វ" ដ.ដ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបង្គាប់រក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ ៧៣៣៥ "វ" ដ.ដ ចុះថ្ងៃទី១៩ ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុវ៉ន្ត ហៅ ឆ្លោក បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៦និង៣០នាទី ខ្លួន និងមិត្តភក្តិ ចំនួន០៥នាក់ ដែលមានឈ្មោះ ពន្ធឺ , ឈ្មោះ សំណាង , ឈ្មោះ ណូ និងឈ្មោះ ខ្មៅ បានជួបជុំគ្នាផឹកទឹកត្នោតជូរនៅម្តុំភូមិត្រពាំងឈូក បានមួយសន្ទុះស្រាប់តែឃើញមនុស្សប្រុស ០២នាក់ ចូលមកផឹកទឹកត្នោតជូរដែរ ដោយចង្អុយក្បែរកញ្ចុះរបស់ខ្លួន ។ ក្រោយមកក៏មានមនុស្សប្រុសម្នាក់ក្នុងចំណោម០២នាក់នោះបានដើរទៅបន្ទប់ទឹក ពេលគាត់ដើរមកវិញ ខ្លួនបានហៅគាត់ឱ្យមកអង្គុយផឹកជាមួយនឹងខ្លួនបានមួយកែវ រួចដើរទៅអង្គុយនៅកញ្ចុះរបស់គាត់វិញ បន្តិចក្បួកខ្លួនបានចូលមកអង្គុយផឹកជាមួយគាត់វិញ និងសុំស្គាល់គ្នាតាមរយៈហ្វេសប៊ុកគ្នាទៅវិញទៅមក ។ រហូតដល់ម៉ោងប្រហែល ១៩និង៣០នាទី កន្លែងលក់ទឹកត្នោតជូរបានអស់ទឹកត្នោតជូរ ខ្លួន និងមិត្តភក្តិរួមទាំងមនុស្សប្រុស០២នាក់នោះ ក៏នាំគ្នាទៅផឹកស៊ីនៅបុរីពិភពថ្មីកំបូល១ ដោយមិត្តភក្តិរបស់ខ្លួនឈ្មោះ ពន្ធឺ និងឈ្មោះ សំណាង បានចេញទៅផ្ទះមុន នៅសល់តែខ្លួន , ឈ្មោះ ណូ និងឈ្មោះ ខ្មៅ រួមទាំងមនុស្សប្រុស ០២នាក់ នោះក៏បានផឹកស្រាបៀរអស់ម្នាក់កន្លះកំប៉ុង ក៏កើតមានទំនាស់ពាក្យសម្តីជាមួយនឹងឈ្មោះ ខ្មៅ ហើយមនុស្សប្រុស ០២នាក់ បានជិះម៉ូតូ

ចេញទៅបាត់។ មួយសន្ទុះក្រោយមកស្រាប់តែឃើញមនុស្សប្រុសម្នាក់បានទូរស័ព្ទមកខ្លួនតាមរយៈហ្វេសប៊ុក សួរថានៅឯណា ខ្លួនបានតបវិញថាកំពុងរៀបចំទៅផ្ទះ ហើយមនុស្សប្រុសនោះបានប្រាប់ខ្លួនវិញថា ចាំខ្លួននៅភ្លោងទ្វារវត្តស្ងួនពេជ្រ ពេលនោះខ្លួនបានឱ្យឈ្មោះ ឡៅ បើកម៉ូតូទៅកន្លែងដែលមនុស្សប្រុសនោះណាត់ជួប ។ ពេលទៅដល់មិនបានឃើញមនុស្សប្រុសនោះ ខ្លួនបានជិះម៉ូតូត្រឡប់ទៅផ្ទះវិញ រួចមនុស្សនោះបានទូរស័ព្ទមកខ្លួនម្តងទៀតតាមរយៈហ្វេសប៊ុកថា គាត់ចាំខ្លួននៅភ្លោងទ្វារវត្តស្ងួនពេជ្រ ពេលនោះខ្លួនបានដើរចូលទៅក្នុងផ្ទះយកដាវកែច្នៃកាន់នឹងដៃស្តាំ រួចឡើងជិះម៉ូតូជាមួយឈ្មោះ ឡៅ មកជួបមនុស្សប្រុស០២នាក់នោះនៅភ្លោងទ្វារស្ងួនពេជ្រ ក៏ឃើញមនុស្សប្រុសនោះ ឈ្មោះ ឡៅ បានឈប់ម៉ូតូ ហើយមនុស្សប្រុស០២នាក់នោះ បានដើរសំដៅមករកខ្លួន ពេលនោះមនុស្សប្រុស០២នាក់នោះដើរមកដល់ជិតខ្លួន ទើបបានខ្លួនលើកដាវកាប់ទៅលើក្បាលមនុស្សប្រុស០២នាក់នោះ តែមនុស្សប្រុស០២នាក់នោះលើកដៃរង បណ្តាលឱ្យរបួសត្រូវដៃរួចមនុស្សប្រុសទាំង០២នាក់នោះបានរត់គេចខ្លួន ហើយខ្លួនបានយកដាវកាប់ទៅលើម៉ូតូរបស់មនុស្សប្រុសនោះមួយដាវទៀត រួចឡកខ្លួនជិះម៉ូតូគេចខ្លួន ។ លុះដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៥និង០០នាទី រួបខ្លួនកំពុងនៅក្នុងវត្តកំបូល ស្រាប់តែឃើញសមត្ថកិច្ចចុះមកដល់ ហៅខ្លួនមកសាកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទោក តែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] **សុឃន់** ហៅ **ឡៅ** បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៥ល្ងាច ខ្លួន និងមិត្តភក្តិចំនួន ០៤នាក់ ដែលមានឈ្មោះ ពន្ធឺ , ឈ្មោះ សំណាង , ឈ្មោះ ណូ និងឈ្មោះ [redacted] សុវ៉ន្ត ហៅ ភ្លោក បានជួបជុំគ្នាផឹកទឹកស្មោតជូរនៅម្តុំភូមិត្រពាំងឈូក នៅពេលផឹកអស់មួយកាតូកន្លះ ខ្លួនបានមកផ្ទះដើម្បីរៀបចំបាយទឹកឱ្យបង រួចក៏ចេញមកបន្តផឹកជាមួយគ្នាទៀត តែពេលទៅដល់កន្លែងផឹកស្មោតជូរវិញ ស្រាប់តែមិត្តភក្តិរបស់ខ្លួនទាំងអស់ឈប់ផឹកនៅកញ្ចុះរបស់ខ្លួនឯង បែរជាផឹកជាមួយមនុស្សប្រុស០២នាក់នៅកញ្ចុះជិតគ្នាទៅវិញ ។ ពេលកំពុងផឹកនោះមិនមានរឿងអ្វីទេ គឺជជែកគ្នារាប់អានគ្នាធម្មតា ហើយបន្តផឹកអស់មួយកាតូទៀត ក៏អស់ស្មោតជូរ ទើបបុរស០២នាក់នោះបានបបួលពួកខ្លួនទៅផឹកនៅបុរីពិភពថ្មីកំបូល និងបានឱ្យហ្វេសប៊ុកទៅឈ្មោះ ភ្លោក ដើម្បីទាក់ទងគ្នា។ រួចហើយបុរសទាំង០២នាក់នោះ បានឱ្យខ្លួនទាំង០២នាក់ ទៅចាំនៅបុរីពិភពថ្មីកំបូលមុន ហើយគេទាំង០២នាក់សុំ ទៅអូរឱរអាវសិន ពេលនោះឈ្មោះ ពន្ធឺ និងឈ្មោះ ណាង បានត្រឡប់ទៅផ្ទះវិញហើយ មានតែឈ្មោះ ភ្លោក និងឈ្មោះ ណូ ទេដែលទៅផឹកបន្ត ។ នៅពេលដែលបុរសទាំង០២នាក់ នោះមកដល់ពួកខ្លួនបានផឹកអស់ស្រាបៀរអស់ម្នាក់កន្លះកំប៉ុង ហើយគាត់ទាំង០២នាក់នោះ បានបបួលពួកខ្លួនទៅភ្នំពេញ ប៉ុន្តែពួកខ្លួនឃាត់មិនឱ្យទៅ ក៏ស្រាប់តែបុរសទាំង ០២នាក់ នោះមានម្នាក់បានទម្លាក់កំប៉ុងស្រាបៀរទៅដី ហើយនិយាយថា បើពូកែឃាត់គេឱ្យនៅផឹកបន្តទៅ រួចបុរសទាំង០២នាក់នោះ ក៏បានចេញទៅយកដែក ឬដាវដែលដាក់នៅឈ្នាន់ម៉ូតូដាក់ក្នុងកែបម៉ូតូរបស់គេ ហើយបានជិះម៉ូតូក្រឡឹងពួកខ្លួនដែលកំពុងអង្គុយផឹកនៅស្នងក្នុងបុរីពិភពថ្មី និងបាននិយាយថា បើអ្នកណាខ្លាំងចេញមកក្រៅមក ។ បន្ទាប់មកបុរសទាំង ០២នាក់ នោះក៏ទៅបាត់ រួចគេទាំង០២នាក់ បានគេហ្វេសប៊ុកមករបស់ឈ្មោះ ភ្លោក ឱ្យទៅជួបគេនៅមុខវត្តស្ងួនពេជ្រ បន្ទាប់មកឈ្មោះ ណាង ក៏ទៅផ្ទះ ហើយខ្លួនបានជូនឈ្មោះ ភ្លោក ទៅជួបគេនៅវត្តស្ងួនពេជ្រ ដោយពុំមានអាវុធអ្វីទេ ប៉ុន្តែមិនបានជួបគេទេ ទើបពួកខ្លួនត្រឡប់មកផ្ទះឈ្មោះ ភ្លោក វិញ បានបន្តិចក៏គេតេឱ្យទៅជួបនៅវត្តស្ងួនពេជ្រទៀត ទើបឈ្មោះ ភ្លោក បានយកដាវរបស់គាត់កាន់ជាប់នឹងដៃឱ្យខ្លួនជូនទៅម្តងទៀត ពេលទៅដល់បានឃើញញបុរស ០២ នាក់ នោះ ខ្លួនបានឈប់ម៉ូតូពីក្រោយម៉ូតូរបស់ពួកគេ រួចគេបានដើរសំដៅមកពួកខ្លួន ទើបឈ្មោះ ភ្លោក យកដាវទៅកាប់គេមួយដាវ ប៉ុន្តែមិនដឹងត្រូវកន្លែងណាទេ ហើយបានយកដាវទៅកាប់ម៉ូតូរបស់គេទៀត ពេលពួកគេរត់គេចខ្លួន ។ បន្ទាប់មកពួកខ្លួនបានត្រឡប់មកផ្ទះវិញ ។ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ សមត្ថកិច្ចបានឃាត់ខ្លួន និងឈ្មោះ ភ្លោក ព្រមទាំងដកហូតដាវរបស់ឈ្មោះ ភ្លោក ផងដែរ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជាន់ណា បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង២០នាទី ខ្លួនកំពុងអង្គុយផឹកទឹកត្នោតជូរ ជាមួយឈ្មោះ [redacted] សុភ័ក្រ នៅភូមិត្រពាំងឃ្លោក សង្កាត់កន្ទោក ក៏មានមនុស្សមួយក្រុមមានគ្នាប្រហែល ០៥នាក់ ដែលអង្គុយផឹកក្បែរនោះបានដើរមកជល់កែវ ហើយនិយាយចង់រាប់អានគ្នាជាមួយពួកខ្លួន បន្ទាប់មកអ្នកបន្ទួនក៏បានប្រាប់ឱ្យមនុស្សមួយក្រុមនោះមកអង្គុយផឹកជុំគ្នា ដោយមានបុរសឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក បានសុំគណនីហ្វេសប៊ុករបស់ឈ្មោះ [redacted] សុភ័ក្រ រហូតដល់វេលាម៉ោងប្រហែល ១៩និង០០នាទី ទើបឈប់ផឹកបំបែកផ្លូវគ្នាទៅផ្ទះរៀងៗខ្លួន ។ លុះបានប្រហែល ១០ នាទី ឈ្មោះ [redacted] សុវ័ន្ត បានទូរស័ព្ទជាច្រើនដងមក ឈ្មោះ [redacted] សុភ័ក្រ ឱ្យទៅផឹកជុំគ្នានៅបុរីពិភពថ្មីកំបូល ។ លុះពេលទៅដល់ខ្លួន និងឈ្មោះ ទូច សុភ័ក្រ បានផឹកជាមួយឈ្មោះ ស៊ី សុវ័ន្ត និងបក្ខពួក បានមួយសន្ទុះ ពួកខ្លួនក៏បានសុំទៅផ្ទះមុន ប៉ុន្តែឈ្មោះ [redacted] សុវ័ន្ត និងបក្ខពួក មិនឱ្យទៅ និងបាននិយាយថា និងឱ្យគ្នាទៅកាប់ពួកខ្លួនតាមផ្លូវ រួចពួកខ្លួនក៏ជិះម៉ូតូចេញទៅផ្ទះជួល ហើយឈ្មោះ [redacted] សុវ័ន្ត និងបក្ខពួក បានថតផ្ការូបលេខម៉ូតូរបស់ខ្លួនទុក រហូតដល់វេលាម៉ោងប្រហែល ២៣និង២០នាទី ឈ្មោះ [redacted] សុវ័ន្ត បានទូរស័ព្ទមកខ្លួន ដើម្បីបបួលទៅផឹកទៀត តែពួកខ្លួនប្រកែកមិនព្រមទៅជួបនោះទេ ប៉ុន្តែឈ្មោះ [redacted] សុភ័ក្រ បានឱ្យខ្លួនជូនទៅហ្វូបអីនៅខាងមុខបុរីកំបូល លុះជិះដល់ចំណុចភ្លោងទ្វារវត្តស្ងួនពេជ្រ ក៏មានឈ្មោះ [redacted] សុវ័ន្ត និងឈ្មោះ [redacted] សុឃន់ បានជិះម៉ូតូមកពីក្រោយ ដោយបានយកដាវកាប់ឈ្មោះ [redacted] សុភ័ក្រ ចំនួន ០១ដាវ បណ្តាលឱ្យរបួសដៃ ហើយខ្លួនក៏បានឈប់ម៉ូតូ ក៏ត្រូវជនត្រូវចោទកាប់ចំនួន ០១ដាវ បណ្តាលឱ្យរបួសដៃ និងបណ្តាលឱ្យបាក់ដៃខាងឆ្វេង ទើបខ្លួនដកកូនសោរម៉ូតូ ហើយរត់គេចខ្លួន ចំណែកឈ្មោះ [redacted] សុវ័ន្ត និងឈ្មោះ [redacted] សុឃន់ បានកាប់លើម៉ូតូរបស់ខ្លួនជាច្រើនដាវ រួចគេចខ្លួនបាត់ ។ ក្រោយមកខ្លួនបានទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ អស់រយៈពេល០២សប្តាហ៍ ដោយចំណាយប្រាក់ជាច្រើន តែខ្លួនមិនចាំចំនួននោះទេ ។ ខ្លួនប្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាល និងថ្លៃជួលជុលម៉ូតូ សរុបចំនួន ៣.000 $ (បីពាន់) ដុល្លារអាមេរិក ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៧និង២០នាទី ខ្លួនកំពុងអង្គុយផឹកទឹកត្នោតជូរ ជាមួយឈ្មោះ [redacted] ជាន់ណា នៅភូមិត្រពាំងឃ្លក សង្កាត់កន្ទោក ក៏មានមនុស្សមួយក្រុមមានគ្នាប្រហែល០៥នាក់ ដែលអង្គុយផឹកក្បែរនោះ បានដើរមកជល់កែវ ហើយនិយាយចង់រាប់អានគ្នាជាមួយពួកខ្លួន បន្ទាប់មកអ្នកបន្ទួនក៏បានប្រាប់ឱ្យមនុស្សមួយក្រុមនោះមកអង្គុយផឹកជុំគ្នា ដោយមានបុរសឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក បានសុំគណនីហ្វេសប៊ុករបស់ខ្លួន រហូតដល់វេលាម៉ោងប្រហែល ១៩និង០០នាទី ទើបឈប់ផឹកបំបែកផ្លូវគ្នាទៅផ្ទះរៀងៗខ្លួន ។ លុះបានប្រហែល១០នាទី ឈ្មោះ [redacted] សុវ័ន្ត បានទូរស័ព្ទជាច្រើនដងមកខ្លួនឱ្យទៅផឹកជុំគ្នានៅបុរីពិភពថ្មីកំបូល ។ លុះពេលទៅដល់ ខ្លួន និងឈ្មោះ [redacted] ជាន់ណា បានផឹកជាមួយឈ្មោះ [redacted] សុវ័ន្ត និងបក្ខពួក បានមួយសន្ទុះ ពួកខ្លួនក៏បានសុំទៅផ្ទះមុន ប៉ុន្តែឈ្មោះ [redacted] សុវ័ន្ត និងបក្ខពួក មិនឱ្យទៅ និងបាននិយាយថានឹងឱ្យគ្នាទៅកាប់ពួកខ្លួនតាមផ្លូវ រួចពួកខ្លួនក៏ជិះម៉ូតូចេញទៅផ្ទះជួល ហើយឈ្មោះ [redacted] សុវ័ន្ត និងបក្ខពួក បានថតផ្ការូបលេខម៉ូតូរបស់ខ្លួនទុក រហូតដល់វេលាម៉ោងប្រហែល ២៣និង២០នាទី ឈ្មោះ [redacted] សុវ័ន្ត បានទូរស័ព្ទមកខ្លួន ដើម្បីបបួលទៅផឹកទៀត តែពួកខ្លួនប្រកែកមិនព្រមទៅជួបនោះទេ ។ បន្ទាប់មកខ្លួនបានទៅហ្វូបអីនៅខាងមុខបុរីកំបូល លុះជិះដល់ចំណុចភ្លោងទ្វារវត្តស្ងួនពេជ្រ ក៏មានឈ្មោះ [redacted] សុវ័ន្ត និងឈ្មោះ [redacted] សុឃន់ បានជិះម៉ូតូមកពីក្រោយ ដោយបានយកដាវកាប់មកលើខ្លួន ចំនួន ០១ ដាវ បណ្តាលឱ្យរបួសដៃ ហើយឈ្មោះ ធោម ជាន់ណា ក៏បានឈប់ម៉ូតូ ក៏ត្រូវឈ្មោះ [redacted] សុវ័ន្ត កាប់ចំនួន ០១ដាវ បណ្តាលឱ្យរបួសដៃ ហើយពួកខ្លួនបានរត់គេចខ្លួន ចំណែកឈ្មោះ [redacted] សុវ័ន្ត និងឈ្មោះ [redacted] សុឃន់ បានកាប់លើម៉ូតូរបស់ខ្លួនជាច្រើន

Scanned with CamScanner

ដាវ រួចទើបគេចខ្លួនបាត់ ។ ក្រោយមកកើតហេតុ ខ្លួនបានទៅពេទ្យឯនជននៅបែកចាន ដើម្បីរុំរបួសឱ្យ ចំណែកឈ្មោះ ឆោម ផាន់ណា ដោយមានរបួសធ្ងន់ ខ្លួនបានជូនមកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ ។

ខ្លួនប្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាល ចំនួន ៣.៥០០ $ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក ។

-សាក្សីឈ្មោះ [redacted] ម៉ៅងគា បានឆ្លើយបញ្ជាក់ថា: ខ្លួនជាឪពុរបស់ជនរងគ្រោះឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ [redacted] ផាន់ណា ។ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០៣ និង៣០នាទីព្រឹក ឈ្មោះ [redacted] សុភ័ក្រ និង ឈ្មោះ ឆោម ផាន់ណា បានទូរស័ព្ទមកប្រាប់ខ្លួនថា ត្រូវគេកាប់នៅចំណុចក្បែរភ្លោងទ្វារវត្តស្ងួនពេជ្រ ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ហើយកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ ឮដូចនោះខ្លួនក៏ប្រញាប់ទៅមន្ទីរពេទ្យ ប៉ុន្តែពេលទៅដល់គ្រូពេទ្យមិនឱ្យចូលឡើយ ដោយទាក់ទងតាមរយៈទូរស័ព្ទ ហើយខ្លួនក៏បានសួរនាំទៅកាន់ក្មួយអំពីដំណើរឿង ដោយក្មួយខ្លួនបានប្រាប់ថា ស្គាល់មនុស្សប្រុសម្នាក់ប្រើគណនីហ្វេសប៊ុកឈ្មោះ Bong Plouk និងមានបក្ខពួក ដែលបានយកដាវមកកាប់លើពួកគេទាំង០២នាក់ ។ លុះថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០២១ ខ្លួនបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលកន្ទោកតែម្តង ។ រហូតដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១៦និង១៥នាទី សមត្ថកិច្ចទូរស័ព្ទប្រាប់ថាបានធ្វើការឃាត់ខ្លួនជនត្រូវចោទទាំង០២នាក់ ដែលបានធ្វើសកម្មភាពយកដាវកាប់មកក្មួយប្រុសខ្លួនបានហើយ ។

-តាមអំណាននរបាយការណ៍សំយោគលេខ ០៣៤/២១ រ.ប.ក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌកំបូល បានធ្វើសេចក្តីសន្និដ្ឋានថា: ឈ្មោះ [redacted] សុវ៉ាត្ត ហៅ ឆ្នោក អាទ ប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] សុឃន់ ហៅ ឡៅ អាទ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ប្រាកដមែន ។

-តាមអំណានកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១១៥៣ រ.វ.ត ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ មានស្នាមមេដៃជនជាប់ចោទឈ្មោះ [redacted] សុវ៉ាត្ត ហៅ ឆ្នោក នៅសាលាដំបូង និងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ រួមមាន:

១.ម៉ូតូ ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1IQ-8212 ចំនួន ០១គ្រឿង (មិនប្រក្រតី) , ២.ដាវដែកកែច្នៃ ពណ៌ស ប្រវែងប្រហែល ៥0cm ចំនួន ០១ ដើម ។

-តាមអំណានដីកាសម្រេចប្រគល់វត្ថុចាប់យកលេខ ២៥៥ "ប" ព្រ.ទ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចប្រគល់នូវ ម៉ូតូម៉ាក HONDA DREAM C125 សេរី២០២១ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1IQ-8212 ចំនួន ០១គ្រឿង ឱ្យទៅឈ្មោះ [redacted] ស្រីណាង ដែលត្រូវជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ [redacted] សុវ៉ាត្ត យកទៅប្រើប្រាស់ជាបណ្តោះអាសន្ន ។

សេចក្តីសន្និដ្ឋានស្តីចសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ , ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការនេះ តំណាងអយ្យការយល់ឃើញថា: មានភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុវ៉ាត្ត ហៅ ឆ្នោក អាទ ប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] សុឃន់ ហៅ ឡៅ អាទ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិខ្មែរ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។ តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្តាពរទុកនៅដដែល និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី ឈឹម ឃុណង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក ធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលរួចមក ឃើញថាកូនក្តីរបស់ខ្លួនបានធ្វើឃ្លាតភាពគ្រប់ដំណាក់កាលនៃនីតិវិធី ដោយទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្ត ។ កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រ រៀនសូត្របានតិចតួច ប្រព្រឹត្តឡើងដោយខ្វះការត្រិះរិះពិចារណា ។ ដូច្នេះខ្លួនស្នើសុំឱ្យតុលាការសម្រេចជួយសម្រាលទោសដល់កូនក្តីខ្លួនផង ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សុឃន់ ហៅ ឡៅ ធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ និងបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ឃើញថាកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តអំពើចោទប្រកាន់នោះទេ ពីព្រោះកូនក្តីរបស់ខ្លួនមិនបានដឹងថាជនជាប់ចោទឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក មានលាក់ដាវនៅក្នុងអាវឡើយពេលដែលជិះម៉ូតូចេញមក ដោយកូនក្តីខ្លួនបានត្រឹមតែបើកម៉ូតូដឹកឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក ទៅជាមួយគ្នា ហើយពេលទៅដល់កូនក្តីរបស់ខ្លួននៅអង្គុយលើម៉ូតូ ដោយមិនបានចូលទៅកាប់លើជនរងគ្រោះដែរ ដូចដែលជនរងគ្រោះទាំងពីរនាក់បានឆ្លើយផងដែរ ។ ហេតុដូចនេះខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនបានរួចផុតពីបទចោទប្រកាន់ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ ។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុវ័ន្ត បានសំណូមពរសុំឱ្យតុលាការ មេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] សុឃន់ បានសំណូមពរសុំឱ្យតុលាការ មេត្តាសម្រេចឱ្យខ្លួនបានរួចផុតពីបទចោទប្រកាន់ទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩០៤ "ប"ដ.ដ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនត្រូវចោទ: ឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក ភេទ ប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] សុឃន់ ហៅ ឡៅ ភេទ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិ ខ្មែរ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ មកធ្វើការជំនុំជម្រះទៅតាមច្បាប់ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្លោក បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៦និង៣០នាទី ខ្លួន និងមិត្តភក្តិ ចំនួន០៤នាក់ ដែលមានឈ្មោះ ពន្លឺ , ឈ្មោះ សំណាង , ឈ្មោះ ណូ និងឈ្មោះ ឡៅ បានជួបជុំគ្នាផឹកទឹកត្នោតជូរនៅម្តុំភូមិត្រពាំងឈូក បានមួយសន្ទុះស្រាប់តែឃើញមនុស្សប្រុស ០២នាក់ ចូលមកផឹកទឹកត្នោតជូរដែរ ដោយចង្អុលក្បែរកញ្ចុះរបស់ខ្លួន ។ ក្រោយមកពួកខ្លួនបានសុំរាប់អានគ្នា និងអង្គុយ

ផឹកជុំគ្នា និងបានសុំហ្វេសប៊ុកគ្នាទៅវិញទៅមក ។ ក្រោយពីផឹកទឹកស្នោតជូរហើយ ពួកខ្លួនបាននាំគ្នាទៅផឹកស្រាបៀរនៅបុរីពិភពថ្មីកំបូល១ បន្តទៀត ហើយក៏កើតជាទាស់សំដីគ្នារវាង ហើយមនុស្សប្រុស ០២នាក់ បានជិះម៉ូតូចេញទៅបាត់ ។ មួយសន្ទុះ មនុស្សប្រុសម្នាក់បានទូរស័ព្ទមកខ្លួនតាមរយៈហ្វេសប៊ុក ឱ្យពួកខ្លួនទៅជួបនៅក្លោងទ្វារវត្តស្ងួនពេជ្រ ពេលនោះខ្លួនបានឱ្យឈ្មោះ ខ្មៅ ។ ពេលទៅដល់មិនបានឃើញមនុស្សប្រុសនោះ ខ្លួនបានជិះម៉ូតូត្រឡប់ទៅផ្ទះវិញ រួចមនុស្សនោះបានទូរស័ព្ទមកខ្លួនម្តងទៀត ថាគាត់ចាំខ្លួននៅក្លោងទ្វារវត្តស្ងួនពេជ្រ ពេលនោះខ្លួនបានដើរចូលទៅក្នុងផ្ទះយកដាវកែច្នៃកាន់នឹងដៃស្តាំ រួចឡើងជិះម៉ូតូជាមួយឈ្មោះ ខ្មៅ មកជួបមនុស្សប្រុស០២នាក់នោះនៅក្លោងទ្វារស្ងួនពេជ្រ ក៏ឃើញមនុស្សប្រុសនោះ ឈ្មោះ ខ្មៅ បានឈប់ម៉ូតូ ហើយមនុស្សប្រុស០២នាក់នោះបានដើរសំដៅមករកខ្លួន ទើបបានខ្លួនលើកដាវកាប់ទៅលើក្បាលមនុស្សប្រុស០២នាក់នោះ បណ្តាលឱ្យរបួសត្រូវដៃ រួចមនុស្សប្រុសទាំង០២នាក់នោះបានរត់គេចខ្លួន ហើយខ្លួនបានយកដាវកាប់ទៅលើម៉ូតូរបស់មនុស្សប្រុសនោះមួយដាវទៀត រួចពួកខ្លួនជិះម៉ូតូគេចខ្លួន ។ លុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៥និង០០នាទី រូបខ្លួនកំពុងនៅក្នុងវត្តកំបូល ស្រាប់តែឃើញសមត្ថកិច្ចចុះមកដល់ ហៅខ្លួនមកសាកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទោក តែម្តង ។ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ អាចឱ្យតុលាការយកមកពិចារណាបាន ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សុឃន់ ហៅ ខ្មៅ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៥ល្ងាច ខ្លួន និងមិត្តភក្តិ ចំនួន ០៥នាក់ បានជួបជុំគ្នាផឹកទឹកស្នោតជូរនៅម្តុំភូមិត្រពាំងឈូក ពេលកំពុងផឹកនោះមិនមានរឿងអ្វីទេ គឺជជែកគ្នារាប់អានគ្នាធម្មតា ហើយបន្តផឹកអស់មួយកាតូទៀត ក៏អស់ស្នោតជូរ ទើបបុរស០២នាក់នោះបានបបួលពួកខ្លួនទៅផឹកនៅបុរីពិភពថ្មីកំបូល និងបានឱ្យហ្វេសប៊ុកទៅឈ្មោះ ប្លោក ដើម្បីទាក់ទងគ្នា រួចហើយបុរសទាំង០២នាក់នោះ បានឱ្យខ្លួនទាំង០២នាក់ ទៅចាំនៅបុរីពិភពថ្មីកំបូលមុន ហើយគេទាំង០២នាក់ សុំទៅផ្ទះអោរអាវសិន ។ ពេលផឹកនោះក៏បានរឿងទាស់សំដីគ្នាបន្តិចបន្តួច បន្ទាប់មកបុរសទាំង០២នាក់ នោះក៏ទៅបាត់ រួចគេទាំង ០២នាក់ បានគេហ្វេសប៊ុកមករបស់ឈ្មោះ ប្លោក ឱ្យទៅជួបគេនៅមុខវត្តស្ងួនពេជ្រ ហើយខ្លួនបានជូនឈ្មោះ ប្លោក ទៅជួបគេនៅវត្តស្ងួនពេជ្រ ដោយពុំមានអាវុធអ្វីទេ ប៉ុន្តែមិនបានជួបគេទេ ទើបពួកខ្លួនត្រឡប់មកផ្ទះឈ្មោះ ប្លោក វិញ ។ បានបន្តិចគេតេឱ្យទៅជួបនៅវត្តស្ងួនពេជ្រទៀត ទើបឈ្មោះ ប្លោក បានយកដាវរបស់គាត់កាន់ជាប់នឹងដៃ ឱ្យខ្លួនជូនទៅម្តងទៀត ពេលទៅដល់បានឃើញបុរស ០២ នាក់ នោះ ខ្លួនបានឈប់ម៉ូតូពីក្រោយម៉ូតូរបស់ពួកគេ រួចគេបានដើរសំដៅមកពួកខ្លួន ទើបឈ្មោះ ប្លោក យកដាវទៅកាប់គេមួយដាវ ប៉ុន្តែមិនដឹងត្រូវកន្លែងណាទេ ហើយបានយកដាវទៅកាប់ម៉ូតូរបស់គេទៀត ពេលពួកគេរត់គេចខ្លួន បន្ទាប់មកពួកខ្លួនបានត្រឡប់មកផ្ទះវិញ ។ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ សមត្ថកិច្ចបានឃាត់ខ្លួន និងឈ្មោះ ប្លោក ព្រមទាំងដកហូតដាវរបស់ឈ្មោះ ប្លោក ផងដែរ ។ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ អាចឱ្យតុលាការយកមកពិចារណាបាន។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ផាន់ណា និងឈ្មោះ [redacted]សុភ័ក្រ បានឆ្លើយប្រហាក់ប្រហែលគ្នាបញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង២០នាទី ពួកខ្លួនកំពុងអង្គុយផឹកទឹកស្នោតជូរ នៅភូមិត្រពាំងឈូក សង្កាត់កន្ទោក ក៏មានមនុស្សមួយក្រុមមានគ្នាប្រហែល០៥នាក់ ដែលអង្គុយផឹកក្បែរនោះបានដើរមកជល់កែវ ហើយនិយាយចង់រាប់អានគ្នាជាមួយពួកខ្លួន និងមកអង្គុយផឹកជាមួយគ្នា ព្រមទាំងសុំគណនីហ្វេសប៊ុកគ្នាទៅវិញទៅមក រហូតដល់វេលាម៉ោងប្រហែល ១៩និង០០នាទី ទើបឈប់ផឹកបំបែកផ្លូវគ្នាទៅផ្ទះរៀងៗខ្លួន ។ លុះបានប្រហែល១០នាទី ឈ្មោះ [redacted]សុវ៉ន្ត បានទូរស័ព្ទជាច្រើនដងមកឱ្យពួកខ្លួនទៅផឹកជុំគ្នានៅបុរីពិភពថ្មីកំបូល ។ ពេលទៅដល់ពួកខ្លួនផឹកបានមួយសន្ទុះ ក៏បានសុំទៅផ្ទះមុន ប៉ុន្តែឈ្មោះ [redacted]សុវ៉ន្ត និងបក្ខពួក មិនឱ្យទៅ និងបាននិយាយថានឹងឱ្យគ្នាទៅកាប់ពួកខ្លួនតាមផ្លូវ រួចពួក

ខ្លួនក៏ជិះម៉ូតូចេញទៅផ្ទះជួល ហើយឈ្មោះ [redacted] សុវ័ន្ត និងបក្ខពួកបានថតផ្ដាកលេខម៉ូតូរបស់ខ្លួនទុក រហូតដល់វេលាម៉ោង ប្រហែល ២៣និង២០នាទី ឈ្មោះ [redacted] សុវ័ន្ត បានទូរស័ព្ទមកបបួលទៅផឹកទៀត តែពួកខ្លួនប្រកែកមិនព្រមទៅជួបនោះទេ ប៉ុន្តែពួកខ្លួនបានទៅហូបអីនៅខាងមុខបុរីកំបូល លុះជិះដល់ចំណុចភ្លោងទ្វារវត្តស្ងួនពេជ្រ ក៏ឃើញឈ្មោះ [redacted] សុវ័ន្ត និង ឈ្មោះ [redacted] សុយន់ បានជិះម៉ូតូមកពីក្រោយ ដោយបានយកដាវកាប់លើពួកខ្លួន បណ្ដាលឱ្យរងរបួសដៃ និងបាក់ដៃខាង អ្វែង ព្រមទាំងខូចខាតម៉ូតូផងដែរ ។ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ និងរបាយ ការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ អាចឱ្យតុលាការយកមកពិចារណាបាន ។

៥-តាមចម្លើយសាក្សីឈ្មោះ [redacted] ម៉េងគា បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ប្រហែល ០៣ និង៣០នាទីព្រឹក ឈ្មោះ [redacted] សុភ័ក្រ និងឈ្មោះ ឆោម ជាន់ណា បានទូរស័ព្ទមកប្រាប់ខ្លួនថា ត្រូវគេកាប់នៅ ចំណុចក្បែរភ្លោងទ្វារវត្តស្ងួនពេជ្រ ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ហើយកំពុងសម្រាក ព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ ពួកខ្លួនក៏ប្រញាប់ទៅមន្ទីរពេទ្យ ប៉ុន្តែពេលទៅដល់គ្រូពេទ្យមិនឱ្យចូលឡើយ ដោយទាក់ទងតាមរយៈទូរស័ព្ទ ហើយខ្លួនក៏បានសួរនាំទៅកាន់ក្មួយអំពីដំណើរឿង ដោយក្មួយខ្លួនបានប្រាប់ថាស្គាល់ មនុស្សប្រុសម្នាក់ប្រើគណនីហ្វេសប៊ុកឈ្មោះ Bong Plouk និងមានបក្ខពួក ដែលបានយកដាវមកកាប់លើពួកគេទាំង០២ នាក់ ។ លុះថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០២១ ខ្លួនបានទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលកន្ទោកតែម្ដង ។ រហូតដល់ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០២១ សមត្ថកិច្ចទូរស័ព្ទប្រាប់ថាបានធ្វើការឃាត់ខ្លួនជនត្រូវចោទទាំង០២នាក់ ដែលបានធ្វើសកម្មភាព យកដាវកាប់មកក្មួយប្រុសខ្លួនបានហើយ ។

៦-តាមរបាយការណ៍សំយោគលេខ ០៣៥/២១ រ.ប.ក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ របស់អធិការដ្ឋាន នគរបាលខណ្ឌកំបូល បានធ្វើសេចក្ដីសន្និដ្ឋានថា: ឈ្មោះ [redacted] **សុវ័ន្ត** ហៅ **ឆ្នោក** ភេទ ប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] **សុយន់** ហៅ **ឡៅ** ភេទ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ប្រាកដមែន ។ គប្បីតុលាការពិចារណា ។

៧-តាមចម្លើយរបស់ជនជាប់ចោទ , ដើមបណ្ដឹងរដ្ឋប្បវេណី , សាក្សី , របាយការណ៍សរុបរបស់មន្ត្រីនគរបាល យុត្តិធម៌ និងកំណត់ហេតុចាប់យកវត្ថុតាង មានលក្ខណៈស៊ីសង្វាក់គ្នា បញ្ជាក់ថា: កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ២៣ និង៣០នាទី មានឈ្មោះ [redacted] សុវ័ន្ត ហៅ ឆ្នោក និងឈ្មោះ [redacted] សុយន់ ហៅ ឡៅ ភេទ ប្រុស បានធ្វើសកម្មភាពយកដាវកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] សុភ័ក្រ ភេទ ប្រុស និងឈ្មោះ [redacted] ជាន់ណា ភេទ ប្រុស នៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ បណ្ដាលឱ្យមានរបួស ត្រង់ដៃ រួចក៏នាំគ្នាជិះម៉ូតូរត់គេចបាត់ ហើយឈ្មោះ [redacted] ម៉េងគា ត្រូវជាឪពុករបស់ជនរងគ្រោះបានមកដាក់ពាក្យបណ្ដឹងនៅ ប៉ុស្តិ៍នគរបាលរដ្ឋបាលកំបូល រហូតដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ សមត្ថកិច្ចបានចុះស្រាវជ្រាវឈានដល់ការឃាត់ខ្លួន ជនត្រូវចោទទាំង០២នាក់ ខាងលើ នាំមកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌកំបូល តែម្ដង ។ អំពើរបស់ឈ្មោះ [redacted] **សុវ័ន្ត** ហៅ **ឆ្នោក** និងឈ្មោះ [redacted] **សុយន់** ហៅ **ឡៅ** ជនជាតិខ្មែរ ពិតជាអំពើ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ តាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

៨-តំណាងអយ្យការបានសន្និដ្ឋានថា: មានភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុវ័ន្ត** ហៅ **ឆ្នោក** និង ឈ្មោះ [redacted] **សុយន់** ហៅ **ឡៅ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្ម

ទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ គប្បីតុលាការពិចារណា ។

៩-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សុវ៉ន្ត ហៅ ឆ្លោក ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនបានធ្វើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធី ដោយទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្ត កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រ រៀនសូត្របានតិចតួច ប្រព្រឹត្តឡើងដោយខ្វះការត្រិះរិះពិចារណា ដូច្នេះស្នើសុំឱ្យតុលាការសម្រេចជួយសម្រាលទោសដល់កូនក្តីខ្លួនផង គប្បីតុលាការពិចារណា ។

១០-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សុឃន់ ហៅ ឡៅ ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តអ្នកការចោទប្រកាន់នោះទេ ពីព្រោះកូនក្តីរបស់ខ្លួនមិនបានដឹងថាជនជាប់ចោទឈ្មោះ [redacted] សុវ៉ន្ត ហៅ ឆ្លោក មានណាក់ដាវនៅក្នុងអាវឡើយពេលដែលជិះម៉ូតូចេញមក ដោយកូនក្តីខ្លួនបានត្រឹមតែបើកម៉ូតូដឹកឈ្មោះ [redacted] សុវ៉ន្ត ហៅ ឆ្លោក ទៅជាមួយគ្នា ដោយមិនបានចូលទៅកាប់លើជនរងឡើយ ។ ហេតុដូចនេះខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ ។ តុលាការយល់ឃើញថាការសន្និដ្ឋានរបស់មេធាវីខាងលើនេះ មិនអាចឱ្យតុលាការយកមកពិចារណាបានឡើយ ។

១១-ផ្អែកតាមសំអាងហេតុខាងលើ តុលាការយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុវ៉ន្ត ហៅ ឆ្លោក ភេទ ប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] សុឃន់ ហៅ ឡៅ ភេទ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិ ខ្មែរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

១២-ជនជាប់ចោទឈ្មោះ [redacted] សុវ៉ន្ត ហៅ ឆ្លោក បាននិយាយសំដីចុងក្រោយ សំណូមពរសុំឱ្យតុលាការ មេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង គប្បីតុលាការពិចារណា ។

១៣-ជនជាប់ចោទឈ្មោះ [redacted] សុឃន់ ហៅ ឡៅ បាននិយាយសំដីចុងក្រោយ សំណូមពរសុំឱ្យតុលាការ មេត្តាសម្រេចឱ្យខ្លួនបានរួចផុតពីបទចោទប្រកាន់ តុលាការមិនអាចយកមកពិចារណាបានឡើយ ។

១៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្រ ប្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាល និងសំណងជម្ងឺចិត្ត ចំនួន ៣.៥០០ $ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជាន់ណា ប្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាល និងសំណងជម្ងឺចិត្ត ចំនួន ៣.០០០ $ គប្បីតុលាការពិចារណា ។

១៥-វត្ថុចាប់យករួមមាន:

ក-ម៉ូតូ ម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1IQ-8212 ចំនួន ០១គ្រឿង (មិនប្រក្រតី) ត្រូវបានចៅក្រមស៊ើបសួរ សម្រេចប្រគល់ឱ្យម្ចាស់ដើមរួចហើយ តាមដីកាសម្រេចប្រគល់វត្ថុចាប់យកលេខ ២៥៥ "ប" ព្រ.ទ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ ដូច្នេះតុលាការមិនគប្បីលើកយកមកពិចារណា និងសម្រេចឡើយ ។

ខ-ដាវដែកកែច្នៃ ពណ៌ស ប្រវែងប្រហែល ៥0cm ចំនួន ០១ ដើម ជាវត្ថុដែលជនជាប់ចោទបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ដូច្នេះតុលាការ គប្បីសម្រេចរឹបអូស និងបំផ្លាញចោល តាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

Scanned with CamScanner

ហេតុផ្តេចផ្តើសសម្រេច

១-<u>ផ្តន្ទាទោសលើជនជាប់ចោទ</u>៖ឈ្មោះ [redacted] **សុវ័ន្ត** ហៅ **ណ្ហាក** អាយុ ប្រុស អាយុ ២៣ ឆ្នាំ ជនជាតិ ខ្មែរ និងឈ្មោះ [redacted] **សុឃន់** ហៅ **ឡៅ** អាយុ ប្រុស អាយុ ២០ ឆ្នាំ ជនជាតិ ខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល **០២ (ពីរ) ឆ្នាំ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខវត្តស្ងួនពេជ្រ ផ្លូវបេតុង ភូមិស្ងួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **សុវ័ន្ត** ហៅ **ណ្ហាក** និងឈ្មោះ [redacted] **សុឃន់** ហៅ **ឡៅ** រួមគ្នាសងសំណងថ្លៃថ្នាំព្យាបាល និងសំណងជម្ងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភ័ក្រ** ចំនួន ១០,០០០,០០០ **៛** (**ដប់លានរៀល**) និងដើមបណ្តឹង រដ្ឋប្បវេណីឈ្មោះ [redacted] **ជាន់ណា** ចំនួន ១០,០០០,០០០ **៛** (**ដប់លានរៀល**) ការទាមទារលើសពីនេះលើកចោល ។

៣-វិបអូសវត្ថុចាប់យក៖ ដាវដែកកែច្នៃ ពណ៌ស ប្រវែងប្រហែល ៥០ cm ចំនួន ០១ ដើម ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុវ័ន្ត** ហៅ **ណ្ហាក** , ឈ្មោះ [redacted] **សុឃន់** ហៅ **ឡៅ** , ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភ័ក្រ** និងឈ្មោះ [redacted] **ជាន់ណា** ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និង ត្រា : [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និង ត្រា : [redacted]

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃ អង្គារ ១៣ រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ , ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner